ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០១៨/១៨ ក.ប/ស.ជ.ល.ព.ក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រារព្ធទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨ មេសា

ទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨ មេសា ជាព្រឹត្តការណ៍មួយ ដែលតម្រូវឱ្យប្រទេសជាសមាជិករបស់អង្គការអន្តរជាតិខាងការងារប្រារព្ធឡើងជារៀងរាល់ឆ្នាំ ក្នុងគោលបំណងផ្សព្វផ្សាយអំពីទំហំនៃគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ និងបំផុសការយល់ដឹងជាសាធារណៈស្តីពីសុខភាពនិងសុវត្ថិភាពការងារ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៅកន្លែងធ្វើការ ព្រមទាំងទាញការគាំទ្រពីស្ថាប័នពាក់ព័ន្ធ អង្គការនិយោជក និងអង្គការកម្មករនិយោជិត។ ទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨ មេសា នាឆ្នាំនេះ ប្រារព្ធធ្វើឡើងក្រោមប្រធានបទ "ភាពងាយរងគ្រោះផ្នែកសុខភាព និងសុវត្ថិភាពការងាររបស់កម្មករវ័យក្មេង"។

ឆ្នាំនេះជាលើកទី១៣ ហើយដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំប្រារព្ធទិវានេះ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃច័ន្ទ ៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨ នៅតំបន់អភិវឌ្ឍន៍វិហារសួគ៌ (7NG) ខេត្តកណ្តាល។

ដើម្បីរៀបចំការប្រារព្ធទិវាខាងលើនេះ ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ និងអធិកអធមថែមទៀត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដូចខាងក្រោម៖

១. មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង ២៥ រាជធានី-ខេត្ត ត្រូវធ្វើសេចក្តីជូនដំណឹងទៅដល់គ្រប់អង្គការវិជ្ជាជីវៈរបស់និយោជក ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ព្រមទាំងកម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យបានទទួលនូវពត៌មាននេះ។

២. គ្រប់អង្គការវិជ្ជាជីវៈរបស់និយោជក ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ ត្រូវធ្វើការចងបដាពាក្យស្លោកតាមខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ
- ភាពងាយរងគ្រោះផ្នែកសុខភាព និងសុវត្ថិភាពការងាររបស់កម្មករវ័យក្មេង
- ត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅគ្រប់កន្លែងធ្វើការ
- សុវត្ថិភាពការងារ ជាអាទិភាពទីមួយរបស់យើង
- រួមគ្នាកសាងវប្បធម៌ នៃការបង្ការសុខភាព និងសុវត្ថិភាពការងារ
- រួមគ្នាការពារសិទ្ធិការងារ និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសការងារប្រកបដោយសុវត្ថិភាព



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- ចូរតាមមើលជាប្រចាំអំពីវិធានការបង្ការនានា ដើម្បីកុំឱ្យមានបាតុភូតមហន្តរាយនៅកន្លែងការងារ
- មានសុវត្ថិភាពការងារ គឺគ្មានគ្រោះថ្នាក់ការងារ
- ភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការជាក្តីកង្វល់របស់យើងទាំងអស់គ្នា
- ធានាឱ្យគ្រប់កន្លែងការងារមានសុវត្ថិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កន្លែងការងារប្រកបដោយសុខភាព និងសុវត្ថិភាពការងារល្អ នាំឱ្យកើនផលិតភាព និងប្រាក់ចំណូល
- គន្លឹះឈានទៅរកសុវត្ថិភាពការងារ គឺស្ថិតនៅក្នុងដៃរបស់លោកអ្នក
- វិធានសុវត្ថិភាពការងារជាមធ្យោបាយប្រសើរបំផុតនៅកន្លែងធ្វើការ
- និយោជកត្រូវផ្តល់សម្ភារការពារបុគ្គលដល់កម្មករនិយោជិត
- រួមគ្នាកាត់បន្ថយគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ
- ការឈឺចាប់កើតចេញពីកន្លែងធ្វើការងារដែលគ្មានសុវត្ថិភាព
- ជីវិតរបស់ខ្ញុំ ការងាររបស់ខ្ញុំ និងការងារប្រកបដោយសុវត្ថិភាពរបស់ខ្ញុំ
- ការងារសមរម្យ គឺជាការងារប្រកបដោយសុវត្ថិភាព
- សុវត្ថិភាពការងារជាជម្រើសដែលអ្នកត្រូវជ្រើសរើសជាចាំបាច់
- រួមគ្នាការពារហានិភ័យដែលកើតឡើងដោយភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការ
- បង្ការ និងទប់ស្កាត់មេរោគអេស៍/ជំងឺអេដស៍ និងលុបបំបាត់ការរើសអើងនៅកន្លែងការងារ
- គ្រឿងញៀនបំផ្លាញសុខភាព និងអនាគតរបស់យើង
- យើងរួមគ្នា ដើម្បីលុបបំបាត់ពលកម្មកុមារ
- រួមគ្នាលុបបំបាត់ពលកម្មកុមារ ដើម្បីសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម
- មិនត្រូវឱ្យកុមារធ្វើការងារប្រកបដោយគ្រោះថ្នាក់ និងបញ្ចប់ពលកម្មកុមារ
- យើងរួមគ្នាបង្កើនការយកចិត្តទុកដាក់លើកុមារ ដើម្បីអភិវឌ្ឍធនធានមនុស្ស និងគោលដៅឆ្ពោះទៅរកការបញ្ចប់ពលកម្មកុមារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមអំពាវនាវដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិតកម្ពុជា និងពលករបរទេសទាំងអស់ចូលរួមប្រារព្ធ និងអបអរសាទរ ទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨ មេសា ក្នុងបរិយាកាសសោមនស្សរីករាយ សាមគ្គីភាព និងភាតរភាព។

ទទួលបានសេចក្តីជូនដំណឹងខាងលើនេះ គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់ ត្រូវរៀបចំចាត់តាំងអនុវត្តន៍ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធិភាពខ្ពស់។

ថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៨
រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- គ្រប់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
- ឯកសារ-កាលប្បវត្តិ